# សាធារណរដ្ឋប្រជាមានិតកម្ពុជា

ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

លេខ ១០ ន-ក៥៦៦-៨៥

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៨៥

## សារាចរ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

-សមមិត្តប្រធានតុលាការប្រជាជនខេត្ត-ក្រុង

-សមមិត្តរដ្ឋអាជ្ញាអមតុលាការប្រជាជនខេត្ត-ក្រុង

**<u>កម្មវត្ថុ</u>** សេចក្តីណែនាំអំពីរបៀបចាត់ការ និងនិតិវិធិសម្រាប់អយ្យការ និងតុលាការប្រជាជនខេត្ត-ក្រុង

ដើម្បីជៀសវាងការភ័ន្តច្រឡំ ការបកស្រាយមិនឯកភាពគ្នាក្នុងការប្រើពាក្យ សម្រេចលើកលែងចោទប្រកាន់ និងមិនចោទប្រកាន់ជនប្រព្រឹត្តបទល្មើស ដែលបានចែងក្នុងសារាចរណែនាំលេខ១០៤៨ ក.យ.ធ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៨២ របស់ក្រសួងយុត្តិធម៌ និងដើម្បីអោយតុលាការដំណើរការជំនុំជម្រះបានត្រឹមត្រូវនូវរឿងព្រហ្មទណ្ឌដែលមានជនប្រព្រឹត្តបទល្មើសជាអនីតិជន និងជាជនវិកលចរិត ក្រសួងយុត្តិធម៌មានកាតព្វកិច្ចធ្វើសេចក្តីណែនាំដូចតទៅៈ

**-អំពីសេចក្តីសម្រេចពីការចោទប្រកាន់ ឬ មិនចោទប្រកាន់ជនប្រព្រឹត្តបទល្មើស**

អំណឹះតទៅ រដ្ឋអាជ្ញាអមតុលាការប្រជាជនទូទាំងប្រទេស ត្រូវអនុវត្តអោយបានសមស្របតាមចំណុច ២ មាត្រា ៣ នៃច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ រដ្ឋអាជ្ញាត្រូវអនុវត្តលក្ខការណ៍ដូចខាងក្រោមៈ

១-សម្រេចពីការចោទប្រកាន់ជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលរដ្ឋអាជ្ញាយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់អំពើល្មើសនាំមកនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម ធ្វើអោយប៉ះពាល់ដល់របៀបរៀបរយសាធារណៈនិងបានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ។

២-សម្រេចពីការមិនចោទប្រកាន់ជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ករណីដែលរដ្ឋអាជ្ញាយល់ឃើញថាៈ

ក-ពិរុទ្ធភាពមិនគ្រប់គ្រាន់លើជនប្រព្រឹត្តបទល្មើស

ខ-រឿងមានប្រភេទជារដ្ឋប្បវេណី

គ-បទល្មើសព្រហ្មទណ្ឌមានលក្ខណៈតូចតាច ពុំបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម មិនធ្វើអោយប៉ះពាល់ដល់របៀបរៀបរយសាធារណៈ

ឃ-ជនប្រព្រឹត្តបទល្មើសជាជនវិកលចរិត

ង-ជនប្រព្រឹត្តបទល្មើសជាអនីតិជនអាយុតិចជាង ១៤ ឆ្នាំ ។

ចំពោះករណីដែលចែងក្នុងចំណុច ក.ខ.គ. រដ្ឋអាជ្ញាត្រូវអនុវត្តតាមសារាចរណែនាំលេខ ១០៤៨ ក.យ.ធ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៨២ របស់ក្រសួងយុត្តិធម៌ ប៉ុន្តែក្នុងករណីទាំង៣នេះត្រូវប្រើពាក្យ(សម្រេចពីការមិនចោទប្រកាន់)។

ចំពោះជនប្រព្រឹត្តបទល្មើសដែលចែងក្នុងចំណុច ឃ.ង ក្រោយពីការសម្រេចមិនចោទប្រកាន់ រដ្ឋអាជ្ញាត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ដើម្បីសម្រេចអំពីសំណងរដ្ឋប្បវេណី ដែលអ្នកទទួលខុសត្រូវលើ

ជនប្រព្រឹត្តបទល្មើសត្រូវសងឲ្យដើមបណ្តឹង ។ ក្នុងលិខិតបញ្ជូនសំណុំរឿងរដ្ឋអាជ្ញាត្រូវបញ្ជាក់អំពីពិរុទ្ធភាពនិងករណីមិនយកទោសព្រហ្មទណ្ឌមកអនុវត្ត ព្រមទាំងបញ្ជាក់អំពីអ្នកទទួលខុសត្រូវអោយបានច្បាស់លាស់ ។

**II-អំពីនីតិវិធីជំនុំជម្រះ របស់តុលាការប្រជាជន ផ្នែកព្រហ្មទណ្ឌ ចំពោះរឿងដែលមានជនប្រព្រឹត្តបទល្មើស ជាអនីតិជន និងជាជនវិកលចរិត**

តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ត្រូវអនុវត្តលក្ខការណ៍ដូចតទៅៈ

១-ចំពោះជនប្រព្រឹត្តបទល្មើសជាអនីតិជនអាយុតិចជាង ១៤ ឆ្នាំ ក៏ដូចជា អនិតិជនអាយុពី ១៤ ឆ្នាំ ទៅ ១៨ ឆ្នាំ តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ នៅពេលសវនាការត្រូវធ្វើការសួរដេញដោលជាសម្ងាត់ ។

២-នៅគ្រាប់រឿងដែលមានជនជាប់ចោទជាអនីតិជន ឬជាជនវិកលចរិត តុលាការប្រជាជនត្រូវចាត់តាំងដោយឯកឯងនូវមេធាវី ឬអ្នកការពារសិទ្ធិម្នាក់អោយជួយការពារជនជប់ចោទ ជនជាប់ចោទគ្មានលទ្ធភាពនឹងពឹងអ្នកកាពារសិទ្ធិអោយជួយការពារខ្លួនបាន ។

៣-ចំពោះអនិតិជនអាយុតិចជាង ១៨ ឆ្នាំ និងជនវិកលចរឹកដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានរដ្ឋអាជ្ញាសម្រេចមិនចោទប្រកាន់ តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ត្រូវយកចិត្តទុកដាក់ពិនិត្យអោយបានប៉ះចត់អំពីពិរុទ្ធភាព ព្រមទាំងវាយតម្លៃអោយបានត្រឹមត្រូវនូវទំហំនៃការខូចខាតបណ្តាលមកពីអំពើល្មើស មុននឹងឈានចូលដល់ការសម្រេចអំពីសំណងរដ្ឋប្បវេណី ។

**III-កំណត់សម្គាល់**

ក្នុងរឿងព្រហ្មទណ្ឌ មានករណី ២ ទៀត ដែលជនប្រព្រឹត្តបទល្មើសត្រូវបានចាកផុតពីការផ្តន្ទាទោសព្រហ្មទណ្ឌ ប៉ុន្តែត្រូវទៅទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ហើយការសម្រេចអំពីសំណងរដ្ឋប្បវេណីក៏ជាសមត្ថកិច្ចរបស់តុលាការ ប្រជាជនផ្នែកព្រហ្មទណ្ឌដែរ ។

**ករណីទាំង ២ នោះ គឺៈ**

-ករណីជនប្រព្រឹត្តបទល្មើសទទួលមរណភាពមុនពេលជំនុំជម្រះ

-ករណីជនប្រព្រឹត្តបទល្មើសត្រូវ បានទទួលការលើកលែងទោសជាទូទៅ ក្នុងករណីទាំង២ ខាងលើ បើនៅក្នុងសំណុំរឿងមានដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទារសំណងជួសជុលការខូចខាតរដ្ឋអាជ្ញាត្រូវពិនិត្យមើលពិរុទ្ធភាពលើជនប្រព្រឹត្តបទល្មើសជាមុនសិន មុននឹងសម្រេចបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ដើម្បីជំនុំជម្រះអំពីសំណងរដ្ឋប្បវេណី ។

តុលាការប្រជាជនផ្នែកព្រហ្មទណ្ឌ ក៏ត្រូវសម្រេចអំពីពិរុទ្ធភាពដែរ មុននឹងឈានចូលដល់ការសម្រេចអំពីសំណងរដ្ឋប្បវេណី ។

ក្រសួងយុត្តិធម៌ សូមទាញអារម្មណ៍ដល់អយ្យការ និងតុលាការប្រជាជនទូទាំប្រទេសឲ្យយកចិត្តទុកដាក់អនុវត្តតាមសារាចរនេះអោយបានត្រឹមត្រូវបំផុត ព្រមទាំងបញ្ជាក់ថា សារាចរលេខ ១០៤៨ ក.យ.ធ ចុះថ្ងៃទី២៩ ខែតុលាឆ្នាំ ១៩៨២ ស្ថិតនៅជាធរមានលើកលែងតែពាក្យ(សម្រេចលើកលែងចោទប្រកាន់)ដែលត្រូវយកពាក្យ សម្រេចមិនចោទប្រកាន់ មកជំនួសវិញ។

ក្រសួងយុត្តិធម៌សង្ឃឹមថា សេចក្តីណែនាំនេះបានជាបង្អែកក្នុងចំណាត់ការងាររបស់អយ្យការ និងតុលាការប្រជាជន ដើម្បីពង្រឹងនីត្យានុកូលភាព ។

ហត្ថលេខា និងត្រា

**អ៊ុក ប៊ុនឈឿន**